# តើអ្នកអាចរំពឹងអ្វីពីព្រះជាម្ចាស់ ក្នុងពេលឥឡូវនេះ? (តែងសេចក្តីទី៧/៧)

ដោយ Tim Geoffrion

**សេចក្តីពិត ទី៧៖ រំពឹងថានឹងបានការកែរជាថ្មី ខណៈពេលដែលអ្នកទទួលយក ភាពមានដែនកំណត់របស់អ្នក ហើយរង់ចាំព្រះជាម្ចាស់។**



នៅក្នុងសុបិនដែលធ្វើឲ្យខ្ញុំភ្ញាក់ ដែលខ្ញុំបានសរសេរនៅក្នុងអត្ថបទលើកមុនរបស់ខ្ញុំ ខ្ញុំបានឃើញជញ្ជាំងទឹកដ៏ធំមួយ ដែលមើលទៅដូចជាវានឹងបែកធ្លាយនៅពេលណាមួយ ហើយធ្វើឲ្យខ្ញុំរសាត់ទៅ។ ខ្ញុំអាចស្រមៃឃើញការថប់បារម្ភរបស់ខ្ញុំ រីករាលដាលនៅលើភ្នំ ដែលនៅលើដី នៅចំពោះមុខខ្ញុំ។ ខ្ញុំចង់បត់ភួយខ្នប់ក្តីថប់បារម្ភទាំងនោះ ទុកដូចជាខ្ញុំធ្វើដើម្បីផ្ទេរទៅក្នុងព្រះហស្តរបស់ព្រះជាម្ចាស់។ ប៉ុន្តែ ខ្ញុំមិនអាចទេ។ វាធ្ងន់ណាស់! នៅពេលខ្ញុំក្រឡេកមើលកាន់តែជិត ខ្ញុំដឹងថាមានផ្ទាំងថ្មធំមួយ នៅចំកណ្តាលភួយ។ តើខ្ញុំនឹងលើកវាឡើងយ៉ាងដូចម្តេច?

ដំបូង ខ្ញុំមិនដឹងថាត្រូវធ្វើអ្វីទេ។ តែមិនដឹងជាហេតុអ្វី ខ្ញុំចាប់ផ្តើមទៅជិតថ្មធំនោះ។ ខ្ញុំដាក់ដៃលើវាដោយប្រយ័ត្នប្រយែង ហើយអ្វីដែលធ្វើអោយខ្ញុំភ្ញាក់ផ្អើល នោះគឺវាចាប់ផ្តើមរួញបន្តិចម្តងៗ។ ធាតុពិត វាប្រែទៅជាដុំទឹកកកដែលប្រឡាក់ពេញដោយដី ដែលចាប់ផ្តើមរលាយដោយសារការប៉ះរបស់ខ្ញុំ។ វាកាន់តែតូចទៅៗ ហើយខ្ញុំកាន់តែមានអារម្មណ៍ថាធូរស្រាលឡើងៗ។

ក្រោយមក ខ្ញុំដឹងថាសុបិននេះមានន័យយ៉ាងម៉េច។ នៅពេលដែលការថប់បារម្ភរបស់យើងមានបន្ទុកធ្ងន់ពេក មិនអាចលើកតម្កើងព្រះបាន នោះយើងប្រហែលជាត្រូវដោះស្រាយជាមួយនឹងការព្រួយបារម្ភរបស់យើងជាមុនសិន។

ជំនួសឱ្យការដែលគ្រាន់តែប្រតិកម្មទៅនឹងការខ្វល់ខ្វាយ បដិសេធការខ្វល់ខ្វាយ រត់ចេញពីការខ្វល់ខ្វាយ ឬគ្រាន់តែជាអ្នកទោសរបស់ការខ្វល់ខ្វាយ តែយើងអាចប្រមូលភាពក្លាហានរបស់យើង ហើយប្រឈមមុខនឹងការខ្វល់ខ្វាយដោយផ្ទាល់។ នៅពេលដែលយើងស្គាល់ឈ្មោះ (“ប៉ះពាល់”) ការថប់បារម្ភ យើងទំនងជារៀនអ្វីមួយអំពីវា និងខ្លួនយើង ដែលនឹងរំដោះយើងពីអំណាចរបស់វា។ វាប្រហែលជាប្រែជាមិនធំធេង ឬគំរាមកំហែង ដូចអ្វីដែលយើងបានគិត ឬយើងអាចមានការយល់ដឹងអំពីវិធីដោះស្រាយចំពោះវា ឲ្យបានប្រសើរជាងមុន។ ឬបើពុំដូច្នោះទេ យើងគ្រាន់តែអនុញ្ញាតឱ្យកន្លងទៅតែម្តង។

បន្ទាប់មក ភាពផ្សំគ្នានៃការស្គាល់លក្ខណៈនៃការព្រួយបារម្ភរបស់យើង *និង* ការទុកចិត្តថាព្រះនឹងធ្វើសកម្មភាពនោះនឹងដោះលែងហើយកំពុងបន្ត។

**សេចក្តីពិត ទី៧៖ រំពឹងថានឹងបានការកែរជាថ្មី ខណៈពេលដែលអ្នកទទួលយក ភាពមានដែនកំណត់របស់អ្នក ហើយរង់ចាំព្រះជាម្ចាស់។** (**ហេព្រើរ ២:១៥; អេសាយ ៤០:២៨-៣១; អេភេសូរ ៣:២០-២១**)

នៅក្នុងជំពូកមួយ នៃព្រះគម្ពីរ ដែលត្រូវបានគេដកស្រង់ញឹកញាប់បំផុត គឺ អេសាយ ៤0 ផ្តល់នូវការកម្សាន្តចិត្តដល់ជនជាតិអ៊ីស្រាអែល ដែលកំពុងតែត្រូវបានគេដឹកនាំទៅជាឈ្លើយសឹកនៅបាប៊ីឡូន។ ពួកគេមិនអាចធ្វើអ្វីដើម្បីផ្លាស់ប្តូរកាលៈទេសៈរបស់ពួកគេឡើយ។ ពួកគេតប់ប្រមល់ ភ័យខ្លាច និងមានអារម្មណ៍ថា ខ្លួនមានកំហុសធ្ងន់។ ពួកគេបានទទួលរងនូវលទ្ធផល នៃអំពើបាប និងជម្រើសមិនល្អរបស់ពួកគេ។ ដូច្នេះ លោក អេសាយ ក៏បានថ្លែងនូវពាក្យល្បីៗទាំងនេះ ឥឡូវនេះ៖

> តើឯងមិនបានដឹង តើមិនបានឮទេឬអី ថាព្រះដ៏គង់នៅអស់កល្បជានិច្ច គឺព្រះយេហូវ៉ា ជាព្រះដែលបានបង្កើតផែនដី រហូតដល់ចុងបំផុត ទ្រង់មិនដែលល្វើយឡើយ ក៏មិនដែលអស់កំឡាំងផង គ្មានអ្នកណាអាចស្ទង់យល់យោបល់របស់ទ្រង់បានទេ។ ទ្រង់រមែងចំរើនកំឡាំង ដល់អ្នកដែលល្វើយ ហើយចំណែកអ្នកដែលគ្មានកំឡាំងសោះ នោះទ្រង់ក៏ប្រទានឲ្យ។ ទោះទាំងពួកជំទង់ គេនឹងល្វើយហើយនឿយហត់ទៅបាន ពួកកំឡោះក៏នឹងដួលជ្រលាកបានផង។ តែអស់អ្នកណាដែលសង្ឃឹមដល់ព្រះយេហូវ៉ាវិញ នោះនឹងមានកំឡាំងចំរើនជានិច្ច គេនឹងហើរឡើងទៅលើ ដោយស្លាប ដូចជាឥន្ទ្រី គេនឹងរត់ទៅឥតដែលហត់ ហើយនឹងដើរឥតដែលល្វើយឡើយ។
> *អេសាយ ៤០:២៨-៣១*

នៅក្នុងពាក្យទាំងនេះ មានសេចក្តីសង្ឃឹម និងការលើកទឹកចិត្តជាច្រើន។ អ្នកនិងខ្ញុំនឿយព្រួយ ហើយនឿយហត់។ យ៉ាវេហ៍ (ព្រះអម្ចាស់) មិនដែលនឿយហត់ និងកម្លាំងរបស់ទ្រង់ ក៏មិនអាចវាស់ស្ទង់បានដែរ។ នៅពេលដែលយើងប៉ះនឹងជញ្ជាំង ឬត្រូវសង្កត់ក្រោមទំងន់ នៃការព្រួយបារម្ភរបស់យើង នោះយើងត្រូវតែមើលឲ្យហួសពី

ខ្លួនយើង ដោយសម្លឹងមើលទៅព្រះដែលបង្កើតសកលលោកទាំងមូល។ ព្រះដែលគង់នៅអស់កល្ប គឺជាព្រះដែលអាចលើកបន្ទុកធ្ងន់ៗ ហើយកែវិញ្ញាណរបស់យើងឡើងវិញ។

យើងត្រូវតែ «រង់ចាំព្រះអម្ចាស់ (យ៉ាវេហ៍)» ដោយទទួលស្គាល់ដែនកំណត់ និងភាពទន់ខ្សោយក្នុងភាពជាមនុស្ស ហើយដោយដាក់សេចក្តីសង្ឃឹមរបស់យើង លើអ្វីដែលព្រះជាម្ចាស់អាចធ្វើបាន។ ហើយនៅពេលយើងធ្វើដូច្នោះ នោះយើងនឹងមានអារម្មណ៍ធូរស្រាលជាងមុន។ យើងនឹងរកឃើញថា យើងអាចបើកចិត្ត និងគំនិតរបស់យើង ចំពោះព្រះវិញ្ញាណម្តងទៀត។ យើងនឹងប្រែជាស្រស់ស្រាយ និងកាន់តែមានកម្លាំង។ យើងនឹងអាចបំពេញគោលបំណងរបស់យើងក្នុងជីវិត អាចស្គាល់ព្រះ អាចស្រឡាញ់ព្រះ និងអាចបំរើព្រះ។ នៅក្នុងប្រៀបធៀបរបស់ លោកអេសាយ គឺថា យើងនឹង «ហើរឡើងដោយស្លាប ដូចជាឥន្ទ្រី»។ យើងនឹង «រត់ ហើយមិនចេះនឿយហត់ឡើយ»។



*អនុញ្ញាតឲ្យការថប់បារម្ភរបស់អ្នកធ្វើជាគ្រូរបស់អ្នក*

ការថប់បារម្ភ គឺជារឿងធម្មតានៃបទពិសោធន៍ ក្នុងការរស់នៅរបស់មនុស្ស ដែលជារឿយៗមានអារម្មណ៍តានតឹង និងមានបន្ទុកធ្ងន់។ ទោះយ៉ាងណាក៏ដោយ ប្រសិនបើយើងទុកឱ្យការថប់បារម្ភក្លាយជាគ្រូរបស់យើង វាអាចបង្ហាញអ្វីមួយអំពីស្ថានភាព និងការភ័យខ្លាចរបស់យើង ដែលអាចមានប្រយោជន៍។

ឧទាហរណ៍ នៅពេលយើងមានអារម្មណ៍ថប់ព្រួយ នោះច្រើនតែមានន័យថា អ្វីមួយដែលសំខាន់ ត្រូវជួយនឹងគ្រោះថ្នាក់។ យើង ឬនរណាម្នាក់ ឬអ្វីមួយ ដែលយើងយកចិត្តទុកដាក់យ៉ាងខ្លាំង ត្រូវរងការគំរាមកំហែង។ ប្រសិនបើយើងស្ថិតនៅក្នុងគំនិត និងអារម្មណ៍ថប់បារម្ភ យើងនឹងពិបាកចិត្ត។ ប៉ុន្តែ ប្រសិនបើយើងអនុញ្ញាតឱ្យការថប់បារម្ភរបស់យើង ណែនាំយើងឱ្យយល់កាន់តែស៊ីជម្រៅ អំពីគុណតម្លៃ និងតម្រូវការផ្ទាល់ខ្លួនរបស់យើង នោះយើងអាចទទួលបានការយល់ដឹងថ្មី អំពីអ្វីដែលកំពុងកើតឡើង ហើយថាតើមានអ្វី និងពេលណា ដែលយើងអាចធ្វើអ្វីមួយអំពីការថប់បារម្ភនោះ។

ជាក់ស្តែង ខ្ញុំបានឃើញថា វាមានអត្ថប្រយោជន៍ណាស់ ក្នុងការបែងចែកកង្វល់របស់ខ្ញុំ ទៅជាបីប្រភេទ។ ទីមួយ ខ្ញុំត្រូវប្រឈមមុខ និងស្គាល់លក្ខណៈរបស់វា។ បន្ទាប់មក ខ្ញុំត្រូវសម្រេចចិត្តជាមុន សម្រាប់រឿងនីមួយៗ តើមានអ្វីដែលខ្ញុំអាចធ្វើបាន ចំពោះការព្រួយបារម្ភនេះទេ? ដោយផ្អែកលើចម្លើយរបស់ខ្ញុំ នោះខ្ញុំដាក់វាទៅជាផ្នែកមួយនៃប្រភេទទាំងបីនោះ៖ ធ្វើសកម្មភាព រង់ចាំ ឬអនុញ្ញាតឱ្យវាកន្លងបាត់ទៅ។

**<u>ប្រភេទ ទី១: ធ្វើសកម្មភាព</u>**

ប្រសិនបើវាហាក់ដូចជាមានអ្វីដែលខ្ញុំអាចធ្វើបាន ការព្រួយបារម្ភនឹងស្ថិតនៅក្នុងប្រភេទទីមួយ៖ **ធ្វើសកម្មភាព**។ ឧទាហរណ៍ នៅពេលដែល កូវីដ ១៩ ចាប់ផ្តើមរីករាលដាលពាសពេញសហរដ្ឋអាមេរិក ខ្ញុំបារម្ភថា តើគ្រួសារខ្ញុំហើយនិងខ្ញុំនឹងឈឺ រឺក៏ស្លាប់ទេដឹង។ ខ្ញុំបានដឹងភ្លាមៗថា ទោះបីជាខ្ញុំមិនអាចគ្រប់គ្រងការរីករាលដាលនៃមេរោគ យើងក៏អាចព្យាយាមការពារខ្លួនយើងបានដែរ។ ដរាបណាយើងចាត់វិធានការធ្វើអ្វី ដែលអាចធ្វើទៅបាន (ឧទាហរណ៍ ពាក់ម៉ាស លាងដៃអោយបានទៀងទាត់ ឃ្លាតឆ្ងាយពីសង្គម នៅឲ្យមានគម្លាតពីអ្នកដទៃ ជៀសវាងកន្លែងដែលមានមនុស្សច្រើន។) កំរិតនៃការថប់បារម្ភរបស់យើងចាប់ផ្តើមធ្លាក់ចុះ។ គ្រោះថ្នាក់មិនបាត់ទៅមែន ប៉ុន្តែ ការថប់បារម្ភរបស់យើងថយចុះ ព្រោះយើងកំពុងធ្វើអ្វីមួយ ដើម្បីជួយខ្លួនយើង។

**<u>ប្រភេទ ទី២: រង់ចាំ</u>**

ប្រសិនបើការព្រួយបារម្ភ គឺជាអ្វីមួយដែលខ្ញុំមិនអាចធ្វើអ្វីបានទេ ឥឡូវនេះ ខ្ញុំកំពុងរង់ចាំព័ត៌មាន ឬសកម្មភាពរបស់នរណាម្នាក់ បន្ទាប់មក វានឹងចូលទៅក្នុងប្រភេទទី ២៖ **រង់ចាំ**។ ឧទាហរណ៍ តើវិទ្យាស្ថានទេវវិទ្យាមីយ៉ាន់ម៉ា (MIT) នឹងអាចបើកម្តងទៀតក្នុងឆមាសនេះដែរឬទេ? បើដូច្នេះ តើពេលណា? តើការផ្លាស់ប្តូរដែលត្រូវការនឹងជះឥទ្ធិពលដល់គុណភាពអប់រំយ៉ាងដូចម្តេច? តើវាមានសុវត្ថិភាពគ្រប់គ្រាន់ទេ សម្រាប់ខ្ញុំ ក្នុងការធ្វើដំណើរនៅទីនោះ និងទៅរស់នៅប្រទេសមីយ៉ាន់ម៉ាម្តងទៀត នៅខែកញ្ញានេះ?

ខ្ញុំមិនអាចដឹងចម្លើយចំពោះសំណួរទាំងនេះទេ ឥឡូវនេះ។ ខ្ញុំត្រូវរង់ចាំមើលថាតើរដ្ឋាភិបាលមីយ៉ាន់ម៉ា និងរដ្ឋបាល MIT នឹងសម្រេចចិត្តបែបណា។ ក្នុងពេលនេះមិនមានតម្លៃក្នុងការព្រួយបារម្ភ អំពីអ្វីដែលពួកគេគួរធ្វើ ឬអំពីអ្វីដែលខ្ញុំនឹងអាចធ្វើបាន។ ផ្ទុយទៅវិញ ខ្ញុំត្រូវប្រាប់ខ្លួនឯងថា ពេលវេលានឹងមកដល់ ដែលខ្ញុំនឹងដឹងចម្លើយ។ ទំរាំតែដល់ពេលនោះ ខ្ញុំត្រូវរង់ចាំសិន។ ខ្ញុំត្រូវបង្វែរការយកចិត្តទុកដាក់ចំពោះអ្វីដែលខ្ញុំអាចធ្វើអ្វីបានខ្លះ (ប្រភេទទី ១) ហើយរង់ចាំមើល ថាតើព្រះនឹងធ្វើអ្វីខ្លះ។

**<u>ប្រភេទ ទី៣: បណ្តោយឲ្យកន្លងបាត់ទៅ</u>**

ទីបំផុត ច្រើនដងហើយ រឿងដែលខ្ញុំខ្វល់ខ្វាយ គឺមិនអាចគ្រប់គ្រងខ្ញុំបានទាំងស្រុងទេ ហើយគ្មានអ្វីដែលខ្ញុំអាចធ្វើបាននៅឡើយទេ។ ឧទាហរណ៍ ខ្ញុំឆ្ងល់តើនិស្សិត និងមិត្តរួមការងាររបស់ខ្ញុំនៅក្នុងប្រទេសមីយ៉ាន់ម៉ា និងដៃគូពិភពលោកដទៃទៀត នឹងសុខស្បាយដែរ ឬទេ? តើនឹងមានវិបត្តិសេដ្ឋកិច្ចទេ? តើពិភពលោកនឹងជាសះស្បើយពីជំងឺរាតត្បាតទាំងស្រុងទេ? បញ្ហាទាំងនេះកំពុងកើតឡើង។ វាប្រហែលជានៅតែជាការគំរាមកំហែង ដោយគ្មាន

កំណត់។ ការរង់ចាំចម្លើយ អាចនឹងមានជារៀងរហូត។ ដូច្នេះ ខ្ញុំប្រាប់ខ្លួនឯងថា ខ្ញុំនឹងឆ្លងផុតតាមស្ពាននោះ ពេលខ្ញុំទៅដល់។ រហូតដល់ពេលនោះ ប្រសិនបើគ្មានអ្វីដែលខ្ញុំអាចធ្វើបាន ខ្ញុំនឹងអនុញ្ញាតឱ្យវាកន្លងទៅ។ មិនអីទេ។ ខ្ញុំមិនចាំបាច់ព្រួយបារម្ភ អំពីអ្វីដែលខ្ញុំមិនអាចធ្វើបាននោះទេ។



*ក្រុមជំនុំ Holy Sepulchre (ទីក្រុងយេរូសាឡិមចាស់, ប្រទេសអ៊ីស្រាអែល)*

### *មេរៀនសម្រាប់ការអនុវត្តខាងវិញ្ញាណ*

តើបន្ទុករបស់អ្នកសព្វថ្ងៃធ្ងន់ប៉ុណ្ណា?

ប្រសិនបើអ្នកអាចប្រមូលកង្វល់របស់អ្នកជាមួយគ្នា ហើយដាក់វានៅក្នុងព្រះហស្តរបស់ព្រះ ចូរធ្វើបែបនោះទៅ! ប៉ុន្តែប្រសិនបើទម្ងន់ហាក់ដូចជាច្រើនពេក ឬកាលៈទេសៈរបស់អ្នក ហួសហេតុពេក សូមសាកល្បងនេះ៖ ប្រមូលភាពក្លាហានរបស់អ្នក ហើយប្រឈមមុខនឹងការថប់បារម្ភរបស់អ្នក។ កំណត់ប្រភេទ (ប៉ះពាល់) របស់វានីមួយៗ ហើយសួរវាថា "តើឯងចង់អោយខ្ញុំដឹងអ្វីខ្លះពីឯង? តើឯងអាចប្រាប់ខ្ញុំអ្វីខ្លះ ដែលអាចជួយខ្ញុំអោយស៊ូទ្រាំបានប្រសើរជាងនេះ?”

តើមានអ្វី ដែលអ្នកអាចធ្វើបាន ដើម្បីជួយកាត់បន្ថយការព្រួយបារម្ភរបស់អ្នក? បើដូច្នេះ វាដល់ពេលត្រូវ**ធ្វើសកម្មភាព**ហើយ។ ធ្វើអ្វីដែលមាននៅក្នុងខ្លួនអ្នក ដើម្បីជួយខ្លួនឯង។ ប្រសិនបើនៅលើដៃ គ្មានអ្វីដែលអ្នកត្រូវធ្វើឥឡូវនេះទេ បន្ទាប់មក ត្រូវប្រាប់ខ្លួនអ្នកឱ្យ**រង់ចាំ**។ រង់ចាំពេលវេលា ដែលអាចធ្វើសកម្មភាពបានម្តងទៀត ហើយផ្តោតការយកចិត្តទុកដាក់របស់អ្នក ទៅលើអ្វីដែលប្រសើរជាងមុន ក្នុងពេលបច្ចុប្បន្ននេះ។ ទីបំផុត ប្រសិនបើការព្រួយបារម្ភហួសពីការគ្រប់គ្រងរបស់អ្នកទាំងស្រុង ឬគ្រោះថ្នាក់កំពុងកើតមានបន្តបន្ទាប់ ដូច្នេះចូរទុក**ឱ្យវាកន្លងផុតទៅចុះ**។

ពេលដែលអ្នកប្រឈមមុខនឹងភាពមានដែនកំណត់របស់មនុស្ស ដែលមាននៅក្នុងខ្លួនរបស់អ្នកកាន់តែច្រើន នោះកាន់តែព្រមទទួលយកថា អ្នកទទួលខុសត្រូវ ចំពោះអ្វីដែលមាននៅក្នុងអំណាចរបស់អ្នក ដើម្បីធ្វើអ្នកនឹងក្លាយជាអ្នកមានសេរីភាព។ អ្នកនឹងឈប់ព្យាយាមផ្ទុកបន្ទុក ដែលមិនមានន័យសម្រាប់អ្នកដឹក។ អ្នកនឹងសម្រាកនៅក្នុងសេចក្តីស្រឡាញ់ដ៏លើសលប់របស់ព្រះវរបិតា។ អ្នកនឹងចំណាយពេលពេញមួយជីវិតរបស់អ្នក ប្រកបដោយភាពច្នៃប្រឌិត ហើយចែករំលែកសេចក្តីស្រឡាញ់ និងពន្លឺរបស់ព្រះគ្រីស្ទ ជាមួយអ្នកដែលអ្នកយកចិត្តទុកដាក់បំផុត។

បើតាមកម្លាំងផ្ទាល់ខ្លួនរបស់អ្នក ដល់ពេលមួយអ្នកនឹងឈានដល់ដែនកំណត់របស់អ្នក។ នោះហើយជាមូលហេតុដែលធ្វើឱ្យអ្នកល្វើយ និងអស់កម្លាំង។ ដូច្នេះ សូមឈប់ព្យាយាមលើករបស់ដែលធ្ងន់ពេកសម្រាប់អ្នក ហើយឈប់បារម្ភអំពីរឿងដែលមិនអាចកើតឡើងបាន។ ផ្ទេរបន្ទុករបស់អ្នក ទៅក្នុងព្រះហស្តរបស់ព្រះ ហើយរង់ចាំឱ្យទ្រង់ធ្វើតាមវិធី និងពេលវេលារបស់ទ្រង់។ ឈប់បារម្ភខ្លាំងពេក អំពីអ្វីដែលអ្នកមិនអាចគ្រប់គ្រងបាន ឬធ្វើមិនកើត ហើយអនុញ្ញាតឱ្យព្រះវិញ្ញាណបរិសុទ្ធកែដួងចិត្ត ព្រលឹង និងគំនិតរបស់អ្នកជាថ្មីឡើងវិញ។ ពាក្យចាស់មួយពោលថា "ឈប់គិតពីវា ហើយទុកឲ្យព្រះវិញចុះ" នេះពិតជាត្រូវតាមព្រះគម្ពីរ ហើយមានសារប្រយោជន៍មែន។ នេះក៏ជាផ្លូវទៅកាន់សេចក្តីសុខសាន្ត និងក្តីអំណរកាន់តែខ្លាំងឡើងផងដែរ។

ឯយើងរាល់គ្នា យើងជាសាសន៍ស្ថានសួគ៌វិញ ក៏នៅចាំព្រះអម្ចាស់យេស៊ូវគ្រីស្ទ ជាព្រះអង្គសង្គ្រោះ ទ្រង់យាងមកពីស្ថាននោះឯង ២១ ដែលទ្រង់នឹងបំផ្លាស់បំប្រែរូបកាយទាបថោករបស់យើង ឲ្យត្រឡប់ដូចជារូបឧត្តមរបស់ទ្រង់ តាមដែលព្រះចេស្តាទ្រង់ពូកែនឹងបញ្ចុះបញ្ចូលគ្រប់ទាំងអស់ នៅក្រោមអំណាចទ្រង់ផង។

*អេភេសូរ ៣:២០-២១*

*សប្តាហ៍ក្រោយ៖ នៅក្នុងសេចក្តីបញ្ចប់នៃកម្រងតែងសេចក្តីនេះ ខ្ញុំនឹងចែករំលែកពីរឿងរ៉ាវផ្ទាល់ខ្លួនរបស់ខ្ញុំ ស្តីពីរបៀបដែលខ្ញុំរៀនទុកចិត្តព្រះម្តងទៀត បន្ទាប់ពីសោកនាដកម្មផ្ទាល់ខ្លួនរបស់ខ្ញុំ។*

---

**ជួយពួកយើងផ្សព្វផ្សាយពាក្យល្អ**! ដើម្បីឈានដល់មនុស្សកាន់តែច្រើន ដែលត្រូវការការលើកទឹកចិត្តខាងព្រះគម្ពីរ និងជាក់ស្តែងក្នុងពេលមានវិបត្តិសកល នៃជំងឺកូវីដ-១៩ យើងកំពុងបកប្រែអត្ថបទទាំងនេះជា ១០ ភាសាផ្សេងៗគ្នា ដែលប្រើប្រាស់នៅក្នុងផ្នែកផ្សេងៗនៃប្រទេសមីយ៉ាន់ម៉ា ឥណ្ឌា និងសាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោ។ ប្រសិនបើអ្នកការប៉ះពាល់ចិត្ត ឬទទួលបានការលើកទឹកចិត្ត ដោយសារអត្ថបទមួយ ឬច្រើន សូមជួយផ្សព្វផ្សាយដោយចែករំលែកវាជាមួយអ្នកដទៃ និងតាមរយៈការគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់យើង ដើម្បីឈានដល់មនុស្សកាន់តែច្រើនតាមរយៈ **<u>ការបរិច្ចាគទៅព័ន្ធកិច្ចសកល សម្រាប់សេចក្តីជំនឿ សេចក្តីសង្ឃឹម និងសេចក្តីស្រឡាញ់ នៅថ្ងៃនេះ។</u>**

---

ដើម្បីអានអត្ថបទមុនៗ ជាភាសាភូមា ភាសាឈីន ហិណ្ឌី សូមចូលទៅកាន់ "បណ្ណាល័យធនធាន" របស់យើងនៅលើគេហទំព័រ dhlglobal.org ។

ខ្ញុំបានបង្កើតកម្រងសំណេរតែងនេះដើម្បីឆ្លើយតបទៅនឹងវិបត្តិជាសកល នៃជំងឺកូវីដ -២៩ តាមរយៈការបង្រៀនតាមព្រះគម្ពីរ គឺសមហេតុផលនៅក្នុងស្ថានភាពដែលមានការរងទុក្ខលំបាកជាច្រើន របស់មនុស្សជាតិ។ តែងសេចក្ដីនីមួយៗ មានបន្ថែម ជូននូវការអនុវត្តជាក់ស្ដែង ដែលត្រូវបានផ្ដល់ជូន នៅក្នុងសៀវភៅមានចំណងជើងថា *អ្នកដឹកនាំដែលមានព្រះវិញ្ញាណទ្រង់នាំ៖ ប្រាំបួនគោលការណ៍នៃភាពជាអ្នកដឹកនាំ និងគោលការណ៍ខាងព្រលឹងវិញ្ញាណ* ( **HERNDON**, **VA**: **ALBAN INSTITUTE**, ឆ្នាំ ២០០៥ ) ទំព័រ ១៨៤-៩០ ។

Photo Credits:

- All photos, copyright ©Jill Geoffrion, { HYPERLINK "http://jillgeoffrion.com/" } . Used with permission. Photo of multi-ton, dolmen was taken in the Eure-et- Loire valley, France.

Copyright © 2020 Timothy C. Geoffrion, Wayzata, Minnesota. All rights reserved to the author, but readers may freely download, print, forward, or distribute to others, providing that this copyright notice is included.
រក្សាសិទ្ធ © 2020 Timothy C. Geoffrion, ទីក្រុង Wayzata, រដ្ឋមីនេសូតា។ ក្សាសិទ្ធិគ្រប់បែបយ៉ាងជូនចំពោះអ្នកនិពន្ធ ប៉ុន្តែ ប្រិយមិត្តអាចទាញយក បោះពុម្ព បញ្ជូន ឬចែកចាយបន្តដល់អ្នកដទៃទៀតដោយសេរី គ្រាន់តែសូមរក្សាចំណារសម្គាល់នៃការរក្សាសិទ្ធិនេះជាមួយផង។
ប្រែសម្រួលភាសាដោយ: លី ប៊ុនថា